ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរកសិកម្មខេត្តបាត់ដំបង**
**ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម**

# របាយការណ៍
# ស្តីពី ការបូកសរុបលទ្ធផលការងារប្រចាំ ៩ខែ ដើមឆ្នាំ ២០១៦

## ១ ស្ថានភាពរួម

ខេត្តបាត់ដំបងមានស្រុកចំនួន ១៣ និង ក្រុងមួយ ហើយមានវិសាលភាពគ្របដណ្តប់លើផ្ទៃដីធំទូលាយ សម្រាប់ប្រកបរបរកសិកម្ម ។ បើតាមការវិភាគក្បេត្របរិស្ថានដាំដុះ យើងចែកជាបួនតំបន់ធំគឺៈ តំបន់នៅជុំវិញបឹងទន្លេសាប, តំបន់វាលទំនាប, តំបន់ខ្ពង់រាប និងតំបន់អភិរក្សព្រៃឈើ ដែលស្ថិតនៅទិសពាយព្យនៃប្រទេសកម្ពុជា ។ ប្រជាជនភាគច្រើន ប្រកបរបរកសិកម្មមានដូចជាៈ (ការធ្វើស្រែ ចំការ និងចិញ្ចឹមសត្វ...) ដើម្បីជួយទ្រទ្រង់ជីវភាពប្រជាកសិករតាមជនបទ។ មន្ទីរកសិកម្ម ក៏ដូចជាការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មខេត្តបាត់ដំបង បានយកចិត្តទុកដាក់ជួយដល់ប្រជាកសិករ ដោយរួមសហការណ៍នឹងអង្គការនានា ដូចជា អង្គការតាវីតាស អង្គការអភិវឌ្ឍន៍ភូមិ អង្គការទស្សនៈពិភពលោក និងអង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ជាដើម។

## ២ ស្ថានភាពបុគ្គលិក

នៅក្នុងខែកញ្ញានេះ មន្ត្រីរាជការថ្មី ១នាក់ បានផ្ទេរពីមន្ទីរកសិកម្មខេត្តសៀមរាម មកបម្រើការងារនៅក្នុង ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មនៃមន្ទីរកសិកម្មខេត្តបាត់ដំបង។ ដូច្នេះចំនួនមន្ត្រីបំពេញការងារក្នុងការិយាល័យ សរុបចំនួន ១១នាក់ ស្ត្រី ១នាក់ សម្រាប់ចុះពង្រឹងសហគមន៍កសិកម្មដែលមានស្រាប់ និង ចូលរួមមហាសន្និបាតតាមបណ្តាសហគមន៍កសិកម្ម។ ក្នុងចំណោមមន្ត្រីរាជការទាំង ១១នាក់នោះ បានបែងចែក គឺ មន្ត្រីចំនួន ៤នាក់ ទទួលបន្ទុកប្រចាំការ នៅការិយាល័យថ្នាក់ខេត្ត មន្ត្រី ៤នាក់ ចុះចល័តតាមបណ្តាស្រុកដែលមិនមានមន្ត្រីប្រចាំការ និង មន្ត្រី ៣នាក់ ទៀត ត្រូវបានបែងចែក ឲ្យទៅប្រចាំការនៅតាមស្រុកដូចខាងក្រោមៈ

- ប្រចាំការនៅស្រុកថ្មគោល មានមន្ត្រី ១នាក់
- ប្រចាំការនៅស្រុកបវេល មានមន្ត្រី ១នាក់
- ប្រចាំការនៅស្រុកមោងឫស្សី មានមន្ត្រី ១នាក់ ។

ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម ក៏បានសហការជាមួយការិយាល័យកសិកម្មស្រុកទាំង១៣ និងក្រុង១ ដើម្បីរួមគ្នាជួយអភិវឌ្ឍន៍សហគមន៍កសិកម្ម តាមបណ្តាលស្រុក និងក្រុងផងដែរ ។

## ៣ សកម្មភាព និងលទ្ធផលសម្រេចបាន

### ក សន្និបាតបូកសរុបការងារសហគមន៍កសិកម្មប្រចាំឆ្នាំ

បានរៀបចំសន្និបាតបូកសរុបការងារអភិវឌ្ឍន៍សហគមន៍កសិកម្មទូទាំងខេត្តប្រចាំឆ្នាំ ២០១៥ ចំនួន ១លើក នៅសាលប្រជុំមន្ទីរកសិកម្មខេត្ត ដោយមានការចូលរួមពី មន្ត្រី អាជាធរស្រុក-ឃុំ តំណាងអង្គការដៃគូអភិវឌ្ឍន៍ និង តំណាង

សហគមន៍កសិកម្ម សរុបចំនួន ១០៩នាក់ ស្ត្រី ១៥នាក់ ក្នុងនោះ តំណាងសហគមន៍កសិកម្ម មានចំនួន ៦៤នាក់ ស្ត្រី ១១នាក់ ត្រូវជា ៦២សហគមន៍ ។

## ខ ការចុះបញ្ជីសហគមន៍កសិកម្ម

បានចុះបញ្ជីសហគមន៍កសិកម្មថ្មីបានចំនួន ៤សហគមន៍ ដូចជា៖

- សហគមន៍កសិកម្មកកោះ នៅឃុំកកោះ ស្រុកមោងឫស្សី មានសមាជិកសរុបចំនួន ៣១នាក់ ស្រី ២១នាក់ និង ចំនួនភាគហ៊ុនមាន ៤១ហ៊ុន តម្លៃ ៣០,០០០រៀលក្នុងមួយហ៊ុន ស្មើនឹង ប្រាក់ភាគហ៊ុនសរុបចំនួន ១,២៣០,០០០រៀល
- សហគមន៍កសិកម្មរំដួលភ្នំព្រឹក នៅឃុំអូររំដួល ស្រុកភ្នំព្រឹក មានសមាជិកសរុបចំនួន ៣០នាក់ ស្រី ២៨នាក់ និងចំនួនភាគហ៊ុនមាន ៣០ហ៊ុន តម្លៃ ១០០,០០០រៀលក្នុងមួយហ៊ុន ស្មើនឹង ប្រាក់ភាគហ៊ុនសរុបចំនួន ៣,០០០,០០០រៀល
- សហគមន៍កសិកម្មសម្រស់មុខរាហ៍ នៅឃុំមុខរាហ៍ ស្រុករុក្ខគិរី មានសមាជិកសរុបចំនួន ៥៨នាក់ ស្រី ២១នាក់ និងចំនួនភាគហ៊ុនមាន ៦២ហ៊ុន តម្លៃ ៥០,០០០រៀលក្នុងមួយហ៊ុន ស្មើនឹង ប្រាក់ភាគហ៊ុនសរុបចំនួន ៣,១០០,០០០រៀល
- សហគមន៍កសិកម្មពន្លឺថ្មីឃុំព្រៃត្រឡាច នៅឃុំព្រៃត្រឡាច ស្រុករុក្ខគិរី មានសមាជិកសរុបចំនួន ៦២នាក់ ស្រី ៤១នាក់ និងចំនួនភាគហ៊ុនមាន ៦៩ហ៊ុន តម្លៃ ៥០,០០០រៀលក្នុងមួយហ៊ុន ត្រូវជា ប្រាក់ភាគហ៊ុនសរុប ៣,៤៥០,០០០រៀល។

## គ ការចូលរួមមហាសន្និបាតរបស់សហគមន៍កសិកម្ម

បានចូលរួមជាគណៈអធិបតីក្នុងអង្គមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម បានចំនួន ១៦លើក ស្មើនឹងអត្រា ២០.៥១% នៃចំនួនសហគមន៍សរុបក្នុងខេត្ត ដែលមានអ្នកចូលរួមសរុបចំនួន ១,៣៣៨នាក់ ក្នុងនោះស្ត្រី ៨១៨នាក់ រួមមាន៖

- ស្រុកបាណន់ មាន សហគមន៍កសិកម្មពន្លឺថ្មីក្តីសង្ឃឹមនៃកសិករ, កន្ទឺ១ភក្តីរស្មីជលសារ, កន្ទឺ២សាមគ្គីបាណន់មានជ័យ, ពន្លឺចែងមានជ័យ, ភ្នំក្រពើ
- ស្រុកសង្កែ មាន សហគមន៍កសិកម្មចម្រើនផលរាំងកេសី
- ស្រុកមោងឫស្សី មាន សហគមន៍កសិកម្មកកោះ
- ស្រុករុក្ខគិរី មាន សហគមន៍កសិកម្មសម្រស់មុខរាហ៍ និង ពន្លឺថ្មីឃុំព្រៃត្រឡាច
- ស្រុកឯកភ្នំ មាន សហគមន៍កសិកម្មរស្មីស្ពឺក្រោម
- ស្រុកបវេល មាន សហគមន៍កសិកម្មមានជ័យអំពិលប្រាំដើម
- ស្រុកភ្នំព្រឹក មាន សហគមន៍កសិកម្មពន្លឺថ្មីសាមគ្គី បួរសាមគ្គីមានជ័យ ពន្លឺថ្មីពេជ្រចិន្តា និង រំដួលភ្នំព្រឹក ។

## ឃ ការផ្សព្វផ្សាយ និងបណ្តុះបណ្តាល

- បានផ្សព្វផ្សាយគោលគំនិត និងច្បាប់សហគមន៍កសិកម្ម ចំនួន ៤លើក មានអ្នកចូលរួមសរុបចំនួន ៣១៣នាក់ ស្ត្រី ១៨៦នាក់ ស្ថិតនៅភូមិកកោះ ឃុំកកោះ ស្រុកមោងឫស្សី ភូមិព្រៃត្រឡាច ឃុំព្រៃត្រឡាច និងភូមិមុខរាហ៍២ ឃុំមុខរាហ៍ ស្រុករុក្ខគិរី និងភូមិអូរល្ហុង ឃុំអូររំដួល ស្រុកភ្នំព្រឹក
- បានផ្សព្វផ្សាយគំរូលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម ចំនួន ៤លើក មានអ្នកចូលរួមសរុបចំនួន ៣០៨នាក់ ស្ត្រី ១៧៥នាក់ ស្ថិតនៅភូមិកកោះ ឃុំកកោះ ស្រុកមោងឫស្សី ភូមិព្រៃត្រឡាច ឃុំព្រៃត្រឡាច និង ភូមិមុខរាហ៍២ ឃុំមុខរាហ៍ ស្រុករុក្ខគិរី និងភូមិអូរល្ហុង ឃុំអូររំដួល ស្រុកភ្នំព្រឹក

- បានផ្សព្វផ្សាយប្រកាសលេខ ១៨៥ ប្រក.កសក របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពី លក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម បានចំនួន ២លើក ដែលមានអ្នកចូលរួមសរុបចំនួន ៤៣នាក់ ស្រី ១៨នាក់ មកពីសហគមន៍កសិកម្មចំនួន ១៥សហគមន៍ដែលគាំទ្រដោយអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍

- សម្របសម្រួលវគ្គរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម ២លើក មានអ្នកចូលរួម ២៧នាក់ ស្រី ១៤នាក់ មកពីសហគមន៍កសិកម្មចំនួន ៥ គាំទ្រដោយអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍

- បានសម្របសម្រួលវគ្គបណ្តុះបណ្តាល ការចុះបញ្ជីគណនេយ្យសហគមន៍កសិកម្ម ចំនួន ១វគ្គ មានអ្នកចូលរួម ១០នាក់ ស្រី ៦នាក់ មកពីសហគមន៍កសិកម្មចំនួន ២ នៅស្រុកភ្នំព្រឹក គាំទ្រដោយអង្គការទស្សនៈពិភពលោក

- បានសម្របសម្រួលវគ្គបណ្តុះបណ្តាល ផែនការអាជីវកម្ម ចំនួន ១វគ្គ មានអ្នកចូលរួម ៣២នាក់ ស្រី ១៣នាក់ មកពីសហគមន៍កសិកម្មចំនួន ១១សហគមន៍ គាំទ្រដោយអង្គកាតទស្សនៈពិភពលោក ។

## ខ ការពង្រឹងសមត្ថភាពមន្ត្រី

មន្ត្រីការិយាល័យចំនួន ៣នាក់ បានចូលរួមក្នុងសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ចំនួន ៥វគ្គ រួមមាន៖

- មន្ត្រីចំនួន ១នាក់ បានទទួលការបណ្តុះបណ្តាលស្តីពី ការត្រួតពិនិត្យសហគមន៍កសិកម្ម
- មន្ត្រី ១នាក់ បានទទួលការបណ្តុះបណ្តាល ស្តីពី ការប្រើប្រាស់ និង ការគ្រប់គ្រងអនុគេហទំព័រមន្ទីរកសិកម្មខេត្ត នៃគេហទំព័រនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម
- មន្ត្រី ១នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ផលិតកម្មដំណាំស្រូវ និងផលិតកម្មគ្រាប់ពូជស្រូវនៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម កម្ពុជា (កាឌី CARDI)
- មន្ត្រី ១នាក់ បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការផ្សព្វផ្សាយគំរូលក្ខន្តិកៈថ្មីសម្រាប់សហគមន៍កសិកម្ម
- មន្ត្រី ១នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី កំណត់ប្រព័ន្ធក្បៀគ្របរិស្ថាន ។

## ច ការសហការ

បានសហការជាមួយអង្គការនានាចំនួន ៦អង្គការ, គម្រោងអភិវឌ្ឍន៍ចំនួន ២ និងការិយាល័យជំនាញនានាចំនួន ២ ដែលកំពុងគាំទ្រដល់សហគមន៍កសិកម្ម សរុបបានចំនួន ២៦លើក រួមមាន៖

- អង្គការទស្សនៈពិភពលោកកម្ពុជា៖ បានសហការចំនួន ៦លើក គឺ ការចងក្រងជាបណ្តាញសហគមន៍កសិកម្ម ២លើក, ដឹកនាំសហគមន៍កសិកម្មធ្វើទស្សនៈកិច្ចសិក្សានៅសហគមន៍កសិកម្មខេត្តកណ្តាល ១លើក សម្របសម្រួលវគ្គផែនការអាជីវកម្ម ១លើក សម្របសម្រួលវគ្គបណ្តុះបណ្តាលការចុះបញ្ជីគណនេយ្យសហគមន៍ ១លើក និងរៀបចំវេទិការពិភាក្សាអាជីវកម្មសហគមន៍កសិកម្មប្រចាំឆ្នាំ ១លើក

- អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍៖ បានសហការចំនួន ៥លើក គឺ បង្ហាញផែនការឆ្នាំ២០១៦ដល់សហគមន៍កសិកម្ម ១លើក, សម្របសម្រួលវគ្គរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម ២លើក និង ផ្សព្វផ្សាយលក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម ២លើក

- អង្គការជីវិតថ្លៃថ្នូរ៖ បានសហការចំនួន ១លើក គឺ ចូលរួមជាវាគ្មិនផ្សព្វផ្សាយគោលនយោបាយសហគមន៍កសិកម្ម

- សមាគមន៍សិទ្ធិ និងការអភិវឌ្ឍអ្នកភូមិយើង រួមជាមួយសមាគមន៍ដើម្បីអភិវឌ្ឍន៍សហគមន៍ខ្មែរ៖ បានសហការចំនួន ១លើក ស្តីពីផលិតកម្មកសិកម្មក្នុងបរិបទប្រែប្រួលអាកាសធាតុ

- អង្គការព្រហ្មវិហារធម៌៖ បានសហការចំនួន ១លើក ក្នុងការដឹកនាំសហគមន៍កសិកម្មរបស់ខេត្តពោធិ៍សាត់ មកធ្វើទស្សនៈកិច្ចសិក្សា នៅសហគមន៍កសិកម្មកសិករញញឹមក្នុង ស្រុករតនៈមណ្ឌល

- អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព៖ បានសហការចំនួន ១លើក ក្នុងការដឹកនាំសហគមន៍កសិកម្មខេត្តរតនៈគិរី មកធ្វើទស្សនៈកិច្ចសិក្សានៅសហគមន៍កសិកម្មសេដ្ឋកិច្ចបៃតងសំឡូត និងសហគមន៍កសិកម្មសម្រស់កំពង់ល្ពៅក្នុងស្រុកសំឡូត

- បានសហការជាមួយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងបង្កើនផលិតភាពកសិកម្ម (RIAPIP) ក្នុងការជំរុញធ្វើផលិតពូជស្រូវ(ផ្ការំដួល) ដល់សហគមន៍កសិកម្មចំនួន ៥ ដោយផ្តល់ជា ប្រាក់កម្ចីគ្មានការប្រាក់ វគ្គបណ្តុះបណ្តាលស្តីពីផលិតកម្មគ្រាប់ពូជស្រូវនិងការថែទាំគ្រឿងយន្តកសិកម្ម សេវកម្មភ្ជួររាស់ស្ទូង និងប្រមូលផលជាដើម

- បានសហការជាមួយ កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ដើម្បីចូលរួមវិភាគតម្រូវការកសិករ បានចំនួន ៨លើក នៅស្រុកសង្កែ និង ស្រុកថ្មគោល

- ការិយាល័យសវនកម្មនៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ចំនួន ១លើក ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យសហគមន៍កសិកម្មដល់គណៈកម្មាធិការត្រួតពិនិត្យចំនួន ២៣នាក់ ស្រី ៨នាក់ មកពីសហគមន៍កសិកម្មចំនួន ៨សហគមន៍

- នាយកដ្ឋានកសិឧស្សាហកម្ម៖ សហការ ១លើក ក្នុងការសម្របសម្រួលសហគមន៍កសិកម្មចំនួន ២ គឺសហគមន៍កសិកម្មកន្ទឺ១ភក្តីជលសារ និង កន្ទឺ២សាមគ្គីបាណន់មានជ័យ ឲ្យចូលរួមវេទិការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូច និងទីផ្សារនៅស្រុកបាណន់ ។

## ច ការជួបពិភាក្សាពិគ្រោះយោបល់

បានជួបពិភាក្សាពីស្ថានភាពទាក់ទងនឹងសហគមន៍កសិកម្មជាមួយអង្គការដៃគូអភិវឌ្ឍន៍ និងក្រុមហ៊ុននានា ចំនួន ៥ ស្ថាប័ន ដូចជា៖

- អង្គការអ្នកជិតខាងល្អ (Good Neighbors) បានចំនួន ២លើក ស្តីពី នីតិវិធីចងក្រងសហគមន៍កសិកម្ម រៀបចំផែនការបង្កើតសហគមន៍កសិកម្មចំនួន ២សហគមន៍ នៅស្រុកឯកភ្នំ សម្រាប់ឆ្នាំ ២០១៦

- រោងម៉ាស៊ីនស្រូវមាសស White Gold បានចំនួន ១ លើក ស្តីពី ព័ត៌មានសហគមន៍កសិកម្មដែលដាំដុះពូជស្រូវ ផ្ការំដួល

- អគ្គិសនីកម្ពុជា បានចំនួន ១លើក ស្តីពីព័ត៌មានសហគមន៍កសិកម្មក្នុងការប្រើប្រាស់ម៉ាស៊ីនបូមទឹកស្រោចស្រពដំណាំស្រូវ ដើម្បីរៀបចំគម្រោងតភ្ជាប់ចរន្តអគ្គិសនីដល់វាលស្រែសហគមន៍ ក្នុងតម្លៃ ៤៨០រៀល/គីឡូវ៉ាត់ម៉ោង

- សមាគមប្រជាជនកូរ៉េ នៅបាត់ដំបង និងប៉ៃលិន បានចំនួន ១លើក ស្តីពីនីតិវិធីបង្កើតសហគមន៍កសិកម្ម នៅឃុំគ្រែង ស្រុករតនៈមណ្ឌល

- ក្រុមហ៊ុនអាគ្រីបាឌី (Agribuddy) ចំនួន ២លើក ស្តីពី ផែនការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោល តាមសហគមន៍កសិកម្ម ក្នុងការប្រើប្រាស់កម្មវិធីអាគ្រីបាឌីតាមរយៈទូរស័ព្ទស្មាតហ្វូន អំពីទិន្នន័យកសិកម្ម។

## ឆ ស្ថិតសហគមន៍កសិកម្ម

តារាងសង្ខេបទិន្នន័យសហគមន៍កសិកម្មតាមស្រុក/ក្រុង

| ល.រ | ស្រុក/ក្រុង | ចំនួនសហគមន៍ | សមាជិកសហគមន៍ | | អ្នកដឹកនាំសហគមន៍ | | ដើមទុន (រៀល) |
|---|---|---|---|---|---|---|---|
| | | | សរុប (នាក់) | ស្ត្រី (នាក់) | សរុប (នាក់) | ស្ត្រី(នាក់) | |
| ១ | ស្រុកមោងឫស្សី | 7 | 821 | 420 | 64 | 17 | 231,571,200 |
| ២ | ស្រុករុក្ខគិរី | 4 | 268 | 167 | 34 | 17 | 23,290,000 |
| ៣ | ស្រុកគាស់ក្រឡ | 8 | 1,381 | 707 | 76 | 24 | 405,810,500 |
| ៤ | ស្រុកសង្កែ | 7 | 731 | 320 | 59 | 16 | 358,569,180 |
| ៥ | ក្រុងបាត់ដំបង | 3 | 228 | 145 | 21 | 11 | 77,530,400 |
| ៦ | ស្រុកឯកភ្នំ | 2 | 244 | 147 | 16 | 7 | 100,380,609 |
| ៧ | ស្រុកថ្មគោល | 5 | 333 | 186 | 37 | 12 | 56,017,300 |
| ៨ | ស្រុកបវេល | 6 | 913 | 415 | 51 | 22 | 528,202,780 |
| ៩ | ស្រុកភ្នំព្រឹក | 6 | 630 | 319 | 49 | 25 | 519,441,000 |
| ១០ | ស្រុកកំរៀង | 5 | 838 | 414 | 40 | 16 | 766,056,760 |
| ១១ | ស្រុកសំពៅលូន | 6 | 744 | 477 | 44 | 18 | 1,069,527,920 |
| ១២ | ស្រុកសំឡូត | 6 | 1,674 | 1,160 | 65 | 29 | 844,418,300 |
| ១៣ | ស្រុករតនៈមណ្ឌល | 5 | 651 | 342 | 51 | 16 | 399,763,250 |
| ១៤ | ស្រុកបាណន់ | 8 | 1,302 | 725 | 69 | 22 | 976,842,120 |
| សរុប | | 78 | 10,758 | 5,944 | 676 | 252 | 6,357,421,319 |

ដ្យាក្រាមទី១ ចំនួនសហគមន៍កសិកម្ម ផ្អែកតាម ទំហំទ្រព្យសកម្មសរុប



ដ្យាក្រាមទី ២ ចំនួនសហគមន៍កសិកម្ម ផ្អែកតាម ប្រភេទទ្រព្យសម្បត្តិ




ដ្យាក្រាមទី ៣ ចំនួនសហគមន៍កសិកម្ម ផ្អែកតាម ភាពដំណើរការមុខរបរ




ដ្យាក្រាមទី ៤ ចំនួនសហគមន៍កសិកម្ម ផ្អែកតាម ប្រភេទមុខរបរ



## ៤ បញ្ហាប្រឈម និងដំណោះស្រាយ

- សហគមន៍កសិកម្ម ចំនួន ២ មានវិវាទនឹង សមាជិកក្រុម ប្រឹក្សាភិបាលសហគមន៍ដែលធ្វើឲ្យបាត់ប្រាក់សហគមន៍
- សហគមន៍កសិកម្មភាគច្រើន មិនទាន់មានរបាយការណ៍ ប្រចាំឆ្នាំ
- សហគមន៍កសិកម្មភាគច្រើនមិនទាន់មាន ផែនការអាជីវកម្ម សម្រាប់ប្រតិបត្តិការ
- សហគមន៍ភាគច្រើន មិនទាន់បានធ្វើមហាសន្និបាត
- សមត្ថភាពរបស់សហគមន៍ក្នុងការកត់ត្រាបញ្ជីគណនេយ្យនៅមានកម្រិត
- ការផ្លាស់ប្តូរវិញ្ញាបនបត្រថ្មី ដល់សហគមន៍កសិកម្ម ចាស់ទាំង ៧៤ ។

## ៥ សំណូមពរ

- ស្នើសុំ វគ្គបណ្តុះបណ្តាលជំនាញគណនេយ្យដល់មន្ត្រីការិយាល័យ ។

## ៦ ទិសដៅបន្ត

- បង្កើតសហគមន៍កសិកម្មថ្មីចំនួន ១
- ជួយអន្តរាគមន៍ដល់សហគមន៍កសិកម្មដែលជួបបញ្ហា
- ផ្សព្វផ្សាយលក្ខន្តិកៈថ្មីសម្រាប់សហគមន៍កសិកម្ម
- ពង្រឹងផ្នែកទីផ្សារដល់សហគមន៍កសិកម្ម
- ផ្លាស់ប្តូរវិញ្ញាបនបត្រចុះបញ្ជីសហគមន៍កសិកម្មថ្មី
- បន្តសហការជាមួយអង្គការនានា
- បន្តតាមដានសកម្មភាពសហគមន៍
- រៀបចំផែនការសម្រាប់ឆ្នាំ ២០១៧
- សរុបរបាយការណ៍ប្រចាំឆ្នាំ ។

បាត់ដំបង,ថ្ងៃទី២២ខែ កញ្ញា ឆ្នាំ២០១៦

ប្រធានការិយាល័យ

បានឃើញ និង ឯកភាព

បាត់ដំបង,ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០១៦

ប្រធានមន្ទីរ

ឈឹម_វជិរា